THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
Superintendent

ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០២៣

ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយក្នុងការចែករំលែកព័ត៌មានវិជ្ជមានមួយចំនួនដែលទាក់ទងនឹងពិន្ទុនៃការប្រឡង PSSA និង Keystone ឆ្នាំសិក្សា ២០២២-២០២៣ របស់យើង។ នៅថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០២៣ ក្រសួងអប់រំរដ្ឋធិនស៊ីលវេនញ៉ា (PDE) បានចេញផ្សាយ លទ្ធផល នៃ ប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋធិនស៊ីលវេនញ៉ា (PSSA) និងការប្រឡង Keystone ឆ្នាំសិក្សា ២០២២-២០២៣។ ក្រសួងអប់រំបានឃើញពិន្ទុនៃការប្រឡងរបស់សិស្សមានការប្រសើរឡើង ១៣ ផ្នែក ក្នុងចំណោម ១៧ ផ្នែក សម្រាប់សិស្សថ្នាក់ទី ៣ ដល់ទី ១២ រួមទាំងការបង្កើន កម្រិតស្ទាត់ជំនាញ (Proficiency) និងកាត់បន្ថយ កម្រិតក្រោមមូលដ្ឋាន (Below Basic)។

ក្រសួងអប់រំរដ្ឋធិនស៊ីលវេនញ៉ា (PDE) តម្រូវឱ្យសិស្សសាលារដ្ឋធិនស៊ីលវេនញ៉ា ធ្វើតេស្តតាមស្តង់ដារ (standardized assessments) ពីរប្រភេទ៖ ប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋធិនស៊ីលវេនញ៉ា (PSSA) (ឬ ប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋធិនស៊ីលវេនញ៉ាតាមជម្រើសផ្សេង (PASA) សម្រាប់សិស្សពិការ) ក្នុងថ្នាក់ទី ៣ ដល់ទី ៨ និង ការប្រឡង Keystone ក្នុងថ្នាក់ទី ៨ ដល់ទី ១១ នៅពេលបញ្ចប់វគ្គសិក្សាជាក់លាក់មួយចំនួន។ សិស្សថ្នាក់ទីបី ដល់ទីប្រាំបី ប្រឡង PSSAs ផ្នែកភាសាអង់គ្លេស (ELA) និង គណិតវិទ្យា។ សិស្សថ្នាក់ទីបួន និងទីប្រាំបី ក៏ត្រូវប្រឡងផ្នែកវិទ្យាសាស្ត្រផងដែរ។ សូមមើលខាងក្រោមនេះសម្រាប់ចំណុចសំខាន់ៗរបស់ PSSA និង Keystone៖

**PSSA ផ្នែកគណិតវិទ្យា**

- ភាគរយនៃសិស្សថ្នាក់ទី ៣ ដល់ទី ៨ ដែលបានពិន្ទុ កម្រិតស្ទាត់ជំនាញ (Proficient) ឬ កម្រិតខ្ពស់ (Advanced) បានកើនឡើង ៤,២ ភាគរយ ពី ១៦,៥% ក្នុងឆ្នាំសិក្សា ២០២១-២២ ទៅ ២០,៧% ក្នុងឆ្នាំសិក្សា ២០២២-២៣។
- ភាគរយនៃសិស្សថ្នាក់ទី ៣ ដល់ទី ៨ ដែលបានពិន្ទុ ក្រោមមូលដ្ឋាន (Below Basic) បានធ្លាក់ចុះ ៤,៩ ភាគរយ ពី ៦១,៧% ក្នុងឆ្នាំសិក្សា ២០២១-២២ ទៅ ៥៦,៨% ក្នុងឆ្នាំសិក្សា ២០២២-២៣។
- ភាគរយនៃសិស្សថ្នាក់ទី ៣ ដែលបានពិន្ទុ Proficient ឬ Advanced បានកើនឡើង ៥,៧ ភាគរយ ពី ២០,៨% ក្នុងឆ្នាំសិក្សា ២០២១-២២ ទៅ ២៦,៥% ក្នុងឆ្នាំសិក្សា ២០២២-២៣។
- ភាគរយនៃសិស្សថ្នាក់ទី ៣ ដែលបានពិន្ទុ Below Basic ក៏ធ្លាក់ចុះ ៦,៩ ភាគរយ ពី ៥៨,៩% ក្នុងឆ្នាំសិក្សា ២០២១-២២ ទៅ ៥២% ក្នុងឆ្នាំសិក្សា ២០២២-២៣។

**<u>PSSA ផ្នែកអង់គ្លេស</u>**

- ភាគរយនៃសិស្សដែលបានពិន្ទុ កម្រិតស្ទាត់ជំនាញ (Proficient) ឬ កម្រិតខ្ពស់ (Advanced) ក្នុងថ្នាក់ទី ៣ ដល់ទី ៨ នៅដដែល គឺប្រហែល ៣៤%។
- ភាគរយនៃសិស្សថ្នាក់ទី ៣ ដល់ទី ៨ ដែលបានពិន្ទុ ក្រោមមូលដ្ឋាន (Below Basic) បានធ្លាក់ចុះ ១,៩ ភាគរយ ពី ២៨,២% ទៅ ២៦,៤% ក្នុងចន្លោះឆ្នាំសិក្សា ២០២១-២២ និង ២០២២-២៣។
- ភាគរយនៃសិស្សថ្នាក់ទី ៣ ដែលបានពិន្ទុ Proficient ឬ Advanced បានកើនឡើង ២,៩ ភាគរយ ពី ២៨,១% ក្នុងឆ្នាំសិក្សា ២០២១-២២ ទៅ ៣១% ក្នុងឆ្នាំសិក្សា ២០២២-២៣។
- ភាគរយនៃសិស្សថ្នាក់ទី ៣ ដែលបានពិន្ទុ Below Basic លើការប្រឡង PSSA អង់គ្លេស ក៏ធ្លាក់ចុះ ៦,៦ ភាគរយ ពី ៣៨,២% ក្នុងឆ្នាំសិក្សា ២០២១-២២ ទៅ ៣១,៤% ក្នុងឆ្នាំសិក្សា ២០២២-២៣។

**<u>PSSA ផ្នែកវិទ្យាសាស្ត្រ</u>**

- ភាគរយនៃសិស្សថ្នាក់ទី ៣ ដល់ទី ៨ ដែលមាន កម្រិតស្ទាត់ជំនាញ (Proficient) ផ្នែកវិទ្យាសាស្ត្រ បានកើនឡើង ៣,១ ភាគរយ ពី ៣៧,១% ក្នុងឆ្នាំសិក្សា ២០២១-២២ ទៅ ៤០,២% ក្នុងឆ្នាំសិក្សា ២០២២-២៣។
- ភាគរយនៃសិស្សថ្នាក់ទី ៣ ដល់ទី ៨ ដែលបានពិន្ទុ ក្រោមមូលដ្ឋាន (Below Basic) បានធ្លាក់ចុះ ២ ភាគរយ ពី ៣៥,៦% ទៅ ៣៣,៦% ក្នុងចន្លោះឆ្នាំសិក្សា ២០២១-២២ និង ២០២២-២៣។

**<u>Keystone ផ្នែកអក្សរសិល្ប៍</u>**

- ភាគរយនៃសិស្សថ្នាក់ទី ១១ ដែលបានពិន្ទុ កម្រិតស្ទាត់ជំនាញ (Proficient) ឬ កម្រិតខ្ពស់ (Advanced) ផ្នែកអក្សរសិល្ប៍ បានកើនឡើង ៦,៣ ភាគរយ ពី ៤៧,៦% ក្នុងឆ្នាំសិក្សា ២០១៨-១៩ ទៅ ៥៣,៩% ក្នុងឆ្នាំសិក្សា ២០២២-២៣។

**<u>Keystone ផ្នែកជីវវិទ្យា</u>**

- ភាគរយនៃសិស្សថ្នាក់ទី ១១ ដែលបានពិន្ទុ ក្រោមមូលដ្ឋាន (Below Basic) បានធ្លាក់ចុះ ៥,២ ភាគរយ ពី ៤៣,២% ក្នុងឆ្នាំសិក្សា ២០១៨-១៩ ទៅ ៣៨% ក្នុងឆ្នាំសិក្សា ២០២២-២៣។

លើសពីនេះ ភាគរយនៃសិស្សថ្នាក់ទី ១២ ផ្នែកអប់រំអាជីព និងបច្ចេកទេស (CTE) ដែលបានពិន្ទុ កម្រិតមានសមត្ថភាព (competent) ឬខ្ពស់ជាងនេះ លើការប្រឡងមត្ថភាពក្នុងប្រទេសដែលស្របតាមផ្នែកឧស្សាហកម្ម [National Occupational Competency Testing Institute (NOCTI)] បានកើនឡើងពី ៤៣,៤% ក្នុងឆ្នាំសិក្សា ២០២១-២២ ទៅ ៤៩,១% ក្នុងឆ្នាំសិក្សា ២០២២-២៣ មានការកើនឡើង ៥,៧ ភាគរយ។ ក្រសួងអប់រំរដ្ឋផិនស៊ីលវេនញ៉ា (PDE) ត្រូវការ NOCTI ជាការវាយតម្លៃផ្អែកលើឧស្សាហកម្មសម្រាប់ ការអប់រំផ្នែកអាជីព និងបច្ចេកទេស (CTE)។

ការរីកចម្រើនក្នុងសិក្សារបស់សិស្សានុសិស្សយើងស្របតាមការកែលម្អជាលំដាប់នៃគោលដៅគាំទ្ររបស់យើង៖ សុវត្ថិភាព ការមករៀនរបស់សិស្ស ការមកបង្រៀនរបស់គ្រូ ការបោះបង់ការសិក្សា និងអត្រានៃការបញ្ចប់ការសិក្សា។ ជាពិសេស យើងបានបង្កើនចំនួនផ្លូវទៅកាន់សុវត្ថិភាពពី ៦ ក្នុងឆ្នាំសិក្សា ២០២១-២២ ទៅ ១៣ ក្នុងឆ្នាំសិក្សា ២០២២-២៣ ដែលបានបង្កើនការមករៀនជាប្រចាំរបស់សិស្ស ៣ ភាគរយ ពី ៥៧% ក្នុងឆ្នាំសិក្សា ២០២១-២២ ទៅ ៦០% ក្នុងឆ្នាំសិក្សា ២០២២-២៣ បានបង្កើនការមកបង្រៀនជាប្រចាំរបស់គ្រូ ៧ ភាគរយ ពី ៧៧% ក្នុងឆ្នាំសិក្សា ២០២១-២២ ទៅ ៨៤% ក្នុងឆ្នាំសិក្សា ២០២២-២៣ និងកាត់បន្ថយ ការបោះបង់ការសិក្សា (dropouts) របស់សិស្សចំនួន ២៦៥ នាក់ ពីឆ្នាំសសិក្សា ២០២១-២២ ទៅឆ្នាំសិក្សា ២០២២-២៣ នៅពេលដែលធានាថា ៨៦% នៃសិស្សថ្នាក់ទី ១២ បានបំពេញតាមតម្រូវការថ្មីសម្រាប់ការបញ្ចប់ការសិក្សារបស់រដ្ឋ។

ការរីកចម្រើននៃការសិក្សារបស់កូនលោកអ្នកគឺជាការឆ្លុះបញ្ចាំងនៃការចូលរួមដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នក។ លទ្ធផលវិជ្ជមានទាំងនេះគឺជាភស្តុតាងដែលថា ការខិតខំប្រឹងប្រែងរួមគ្នារបស់យើងពិតជាធ្វើឱ្យមានការផ្លាស់ប្តូរ។

សូមអរគុណចំពោះការជ្រើសរើស ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា សម្រាប់ការអប់រំរបស់កូនលោកអ្នក។ យើងទន្ទឹងរង់ចាំសហការជាមួយលោកអ្នក នៅពេលដែលយើងបន្តរៀបចំសិស្សរបស់យើងឱ្យស្រមើស្រមៃ និងសម្រេចនូវអនាគតដែលពួកគេចង់បាន។

ក្នុងភាពជាដៃគូ

*Tony*

Tony B. Watlington Sr., Ed.D.
អគ្គនាយកនៃក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា